សុន្ទរកថាស្ដីពីថ្ងៃ៤កក្កដា
របស់លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក Mussomeli

រាត្រីសួរស្ដី !!!

សូមស្វាគមន៍អស់លោក លោកស្រីដែលបានអញ្ជើញមកកាន់អាគារស្ថានទូតថ្មីរបស់យើង ។ សូមអរគុណអស់លោក លោកស្រីទាំងអស់គ្នាដែលបានអញ្ជើញមកអបអរទិវា ៤ កក្កដាជាមួយយើងខ្ញុំ ។ នេះគឺជាខួបលើកទី ២៣០ នៃការចុះហត្ថលេខា ប្រកាសឯករាជ្យ តែចំពោះយើងជាជនជាតិអាមេរិក យើងនៅតែគិតថាយើងគឺជាប្រជាជាតិមួយ ដែលនៅក្មេងខ្ចី បើទោះបីជាយើងគឺជាប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យជាប់លាប់ និងមានវ័យចំណាស់ជាងគេក៏ដោយ ។

ពិតមែនតែខ្ញុំរីករាយនឹងប្រារព្ធទិវា ៤ កក្កដាក្ដី តែពេលខ្លះខ្ញុំនៅតែមានមន្ទិលថាការប្រារព្ធពិធីនៅថ្ងៃនេះ ធ្វើអោយគេសន្និដ្ឋានដោយខុសថា ការចុះហត្ថលេខាលើសេចក្ដីប្រកាសឯករាជ្យ គឺជាការបញ្ចប់នៃរឿងរ៉ាវទាំងឡាយ ។ ជាការពិត វាមិនមែនជាការបញ្ចប់នៃរឿងរ៉ាវទាំងនោះទេ ។ វាគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ ហើយជាការចាប់ផ្ដើមទាំងមិនទាន់រឹងមាំទៀតផង ។ យើងត្រូវធ្វើការប្រយុទ្ធស្វិតស្វាញប្រាំឆ្នាំទៀតនាពេលនោះ ដែលបន្ទាប់មកភាពគ្មានសណ្ដាប់ធ្នាប់និងភាពច្របូកច្របល់បានកើតឡើងរាប់ឆ្នាំទៀត ។

ក្រោយពីនោះភ្លាម ពោលគឺនៅក្នុងឆ្នាំ ១៧៩៨ សេរីភាពដែលយើងទទួលបានដោយពិបាកនោះ ត្រូវបានគំរាមកំហែងដោយការអនុម័តច្បាប់ស្ដីពីជនបរទេសនិងប្រឆាំងការបះបោរ ។ ច្បាប់ទាំងនេះ បានអនុញ្ញាតិអោយមានការបណ្ដេញចេញនូវជនបរទេសណាដែល "មានគ្រោះថ្នាក់ដល់សន្តិភាព និងសុវត្ថិភាពរបស់សហរដ្ឋអាមេរិក" ហើយជាលទ្ធផលបាននាំដល់ការចាប់ខ្លួនមនុស្សជាង២៥នាក់ ដែលភាគច្រើនជាបណ្ណាធិការកាសែត ហើយកាសែតរបស់គេត្រូវបានបង្ខំអោយបិទទ្វារ ។ ចូរគិតទៅមើលថាតើអង្គការឃ្លាំមើលសិទ្ធិ

មនុស្សឬតំណាងរបស់សហប្រជាជាតិផ្នែកសិទ្ធិមនុស្ស នឹងនិយាយថាដូចម្តេចទៅវិញ អំពីរឿងហ្នឹង !

រឿងទុក្ខព្រួយដដែលនេះកើតមានហើយមានទៀត ក្នុងរយៈពេលជាងមួយរយឆ្នាំក្រោយមក ។ ច្បាប់ស្តីពីចារកម្មនៅឆ្នាំ១៩១៧ បានកំណត់ថាការរិះគន់នយោបាយស្តីពីសង្គ្រាមរបស់រដ្ឋាភិបាលយើង គឺជាបទឧក្រិដ្ឋមួយ ហើយការមិនទុកចិត្តរបស់យើងលើជនបរទេសមានភាពខ្លាំងក្លា រហូតដល់ជនអន្តោប្រវេសន៍អាល្លឺម៉ង់មួយចំនួន ត្រូវបានគេវាយធ្វើបាបឬត្រូវបានគេព្រួតវាយរហូតទាល់តែស្លាប់ក៏មាន ។ អាហារមួយដែលខ្ញុំចូលចិត្តជាងគេ គឺស្ពៃក្តោបជ្រក់ ហើយក្រោយមកត្រូវបានគេដាក់ឈ្មោះជាថ្មីថា "ស្ពៃក្តោបសេរីភាព" ។

មិនដល់ ៣0 ឆ្នាំក្រោយមកទៀត សង្គ្រាមលោកលើកទី ២ ក៏បានចាប់ផ្តើមឡើង ជាមួយនឹងការចាប់ប្រមូលផ្តុំនិងឃុំឃាំងជនជាតិអាមេរិកដើមកំណើតជប៉ុនរាប់ម៉ឺននាក់ និងជនអន្តោប្រវេសន៍អាល្លឺម៉ង់និងអ៊ីតាលីរាប់ពាន់នាក់ ។ បន្ទាប់ពីសង្គ្រាមនោះទៅគឺការចូលមកដល់នៃយុគសម័យ McCarthy ដែលនៅពេលនោះ សិល្បៈករ អ្នកនិពន្ធនិងសូម្បីតែគ្រូបង្រៀនខ្លះ ត្រូវបានគេកត់ចូលក្នុងបញ្ជីខ្មៅ ដែលធ្វើអោយប៉ះពាល់ដល់ជីវិតរស់នៅនិងអាជីពរបស់គេ ។

ហេតុអ្វីក៏ខ្ញុំកកាយប្រវត្តិរឿងមិនល្អនេះឡើង នៅក្នុងឱកាសដែលយើងគួរសប្បាយរីករាយនេះទៅវិញ? សំខាន់ ដោយខ្ញុំគិតថាវាជាសក្ខីភាពបញ្ជាក់អោយឃើញពីភាពខ្លាំងនៃគោលការណ៍របស់យើង និងភាពខ្លាំងរបស់ប្រជាជនអាមេរិក ។ លើសពីនេះទៀត វារំលឹកអោយយើងទាំងអស់គ្នាដឹងថា សេរីភាពនិងលទ្ធិប្រជាធិបតេយ្យមិនងាយស្រួលនឹងរកបាននោះទេ ហើយវារឹតតែពិបាកទៅទៀតក្នុងការថែរក្សាវាអោយបានគង់វង្សនោះ ។ ការការពារសេរីភាពរបស់យើងទាមទារអោយមានការប្រុងប្រយ័ត្នជានិច្ច និងមានភាពក្លាហានយ៉ាងពិសេស ។ មនុស្សជំនាន់មួយមិនអាចធានាអោយមានសេរីភាពសំរាប់មនុស្សជំនាន់

បន្ទាប់នោះទេ ។ ចំណុចចុងក្រោយ ពីព្រោះខ្ញុំគិតថាមានចំណុចជាច្រើន ដែលប្រទេសកម្ពុជាអាចរៀនសូត្រពីការតស៊ូរបស់ប្រជាជនអាមេរិក ដើម្បីទទួលបានសេរីភាពដូចយើង ហើយរៀនសូត្រពីការតស៊ូរបស់យើងដើម្បីថែរក្សាការពារវានៅពេលមានការគំរាមកំហែង ។ ដូចលោកប្រធានាធិបតី Bush បានលើកឡើងនៅក្នុងសុន្ទរកថាចូលកាន់តំណែងក្នុងអាណត្តិទីពីររបស់លោកថា សេរីភាព " គឺជាតំរូវការបន្ទាន់នៃសន្តិសុខរបស់ប្រជាជាតិយើង.....ដូច្នេះវាគោលនយោបាយរបស់សហរដ្ឋអាមេរិក ក្នុងការស្វែងរកនិងគាំទ្រការលូតលាស់នៃចលនានិងស្ថាប័នប្រជាធិបតេយ្យក្នុងគ្រប់ប្រជាជាតិនិងវប្បធម៌ទាំងអស់ " ។ ប្រវត្តិសាស្ត្រប្រទេសអាមេរិក គឺជាការរំលឹកមួយដ៏ល្អថា មនុស្សទាំងអស់គ្នា មិនមែនគ្រាន់តែប្រជាជនដែលរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ប៉ុណ្ណោះទេ គឺស្ថិតនៅក្នុងដំណើរការដែលមានលក្ខណៈជាអចិន្ត្រៃយ៍ក្នុងការថែរក្សា និងការពង្រឹងបន្ថែមទៀតនូវសេរីភាពរបស់គេ ។

យើងជាជនជាតិអាមេរិកសូមចែករំលែកជាមួយប្រជាជនកម្ពុជា នូវបំណងដ៏រឹងមាំក្នុងការពង្រីកសេរីភាពនិងការធានាលទ្ធិប្រជាធិបតេយ្យ ។ សមដូចលោកប្រធានាធិបតី Bush បានមានប្រសាសន៍ផងដែរថា "យើងធ្វើដំណើរទៅមុខប្រកបដោយភាពជឿជាក់ទាំងស្រុងថា នៅទីបំផុតសេរីភាពនឹងទទួលបានជោគជ័យ" ។ ពិតហើយថា យើងមានភាពទន់ជ្រាយហើយប្រព្រឹត្តកំហុសឆ្គងម្តងម្កាល តែយើងទាំងអស់គ្នាមានការតាំងចិត្តថា មិនបោះបង់ មិនចុះចាញ់ហើយជានិច្ចជាកាល តែងតែឈ្នះអ្នកដែលឆក់យកពីយើងទៅនូវសិទ្ធិដែលមិនអាចកាត់ផ្តាច់ចេញបានក្នុងការមានជីវិតរស់នៅ សេរីភាព និងការស្វែងរកសុភមង្គល ។

ដូច្នេះនៅថ្ងៃដ៏វិសេសវិសាលនេះ នៅពេលយើងប្រារព្ធពិធីអបអរសេរីភាព និងលទ្ធិប្រជាធិបតេយ្យរបស់យើង ខ្ញុំសូមលើកកែវឡើងដើម្បីថ្វាយព្រះពរដល់ព្រះមហាក្សត្រ ដល់រាជរដ្ឋាភិបាលកម្ពុជា និងជាពិសេសដល់ប្រជាជនកម្ពុជា សូមអោយទទួលបាននូវផ្លែផ្កា និងផលប្រយោជន៍ផងដែរពីសេរីភាព និងត្រៀមខ្លួនធ្វើការតស៊ូ ដើម្បីសេរីភាពសំរាប់យើងទាំងអស់គ្នា ។